00146579

**Declassified to Public**
**06 September 2012**

ពេទ/Nº 1) 18

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**Royaume du Cambodge**
**Nation Religion Roi**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**
**Chambres Extraordinaires au sein des Tribunaux Cambodgiens**

**ការិយាល័យសហចៅក្រមស៊ើបអង្កេត**
**Office of the Co-Investigating Judges**
**Bureau des Co-juges d'instruction**
**សំណុំរឿងព្រហ្មទណ្ឌ**
**Criminal Case File /Dossier pénal**
**លេខ/No: 002/14-08-2006**
**លេខស៊ើបសួរ/Investigation/Instruction**
**លេខ/No: 001/18-07-2007**

# ដីកាបំបែកសំណុំរឿង
# Separation Order
# Ordonnance de disjonction

យើង **យូ ប៊ុនឡេង** និង Marcel Lemonde សហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

បានឃើញច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤

បានឃើញការបើកការស៊ើបសួរលើឈ្មោះ **កាំង ហ្គេកអ៊ាវ** ហៅ **ឌុច**

បានឃើញវិធាន២១-៤នៃវិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញ

យល់ឃើញថាអង្គហេតុមួយចំនួនក្នុងចំណោមអង្គហេតុដែលមាននៅក្នុងដីកាបញ្ជូនរឿងអោយស៊ើបសួរត្រូវបានប្រព្រឹត្តឡើងនៅក្រៅក្របខ័ណ្ឌ ស ២១ និង អង្គហេតុខ្លះទៀតត្រូវបានប្រព្រឹត្តឡើងក្នុងក្របខ័ណ្ឌនៃដំណើរការរបស់ ស ២១ នេះ។ អង្គហេតុដែលប្រព្រឹត្តឡើងក្រៅក្របខ័ណ្ឌ ស ២១ ទាមទារអោយមានការស៊ើបសួរស៊ីជម្រៅបន្ថែមទៀតដែលការស៊ើបសួរនេះមិនអាចផ្តាច់ចេញពីការស៊ើបសួរដែលធ្វើឡើងចំពោះជនផ្សេងទៀតដែលមានឈ្មោះនៅក្នុងដីកាបញ្ជូនរឿងអោយស៊ើបសួរឡើយ ខណៈដែលអង្គហេតុចោទចំពោះ ឌុច ក្នុងនាមគាត់ជាប្រធាន ស ២១ មានលក្ខណៈមិនស្មុគ្រស្មាញ និង សាមញ្ញបំផុត ហើយអង្គហេតុទាំងនេះមិនត្រូវបានជំទាស់ ពីសំណាក់ជនត្រូវចោទទេ។

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ។
Extraordinary Chambers in the Courts of Cambodia National Road 4 ,Chaom Chau , Dangkao Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax:023 218941
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Chaom CHau, Damgkao, Phnom Penh
Boite postale 71, Phnom Penh. Tel : Tel:+855(0)23 218914 Fax:023 218941

យល់ឃើញថា ដោយពិនិត្យមើលទៅលើការងារដែលបានធ្វើពីមុន ការស៊ើបសួរលើអង្គហេតុដាក់បន្ទុកដល់ **ឌុច** ក្នុងក្របខ័ណ្ឌ ស ២១ នឹងអាចត្រូវបញ្ចប់ក្នុងរយៈពេលប៉ុន្មានខែខាងមុខនេះ ដោយមិនចាំបាច់រង់ចាំលទ្ធផលនៃស៊ើបសួរបន្ថែមទាក់ទងទៅនឹងអង្គហេតុផ្សេងទៀតឡើយ។

យើងត្រូវមានសេចក្តីសម្រេចមួយអោយបានលឿនចំពោះករណី **ឌុច** ដោយហេតុថាជននេះត្រូវបានឃុំខ្លួនបណ្តោះអាសន្ននៅក្នុងក្របខ័ណ្ឌនីតិវិធីផ្សេងអស់រយៈពេល ៨ ឆ្នាំមកហើយ ដូចដែលមានរៀបរាប់នៅក្នុងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នចុះថ្ងៃទី ៣១ កក្កដា ២០០៧។ ម្យ៉ាងវិញទៀត ការបើកសវនាការជាសាធារណៈនៅក្នុងរយៈពេលឆាប់ៗមានសារៈសំខាន់ជាសារវ័ន្ត ដល់ភាពដែលអាចជឿជាក់បានរបស់តុលាការ ដោយពិនិត្យមើលលើអតីតភាពនៃអង្គហេតុនេះ។

យល់ឃើញថា ជាគុណប្រយោជន៍ដល់ដំណើរការល្អនៃការស្វែងរកយុត្តិធម៌ មានការចាំបាច់ដែលត្រូវបំបែកករណី **ឌុច**

## **ហេតុដូចនេះសម្រេច**

បំបែកសំណុំរឿង **ឌុច** ចំពោះអង្គហេតុប្រព្រឹត្តនៅក្នុងក្របខ័ណ្ឌ **ស ២១** និងប្រកាសថាផ្នែកនេះនៃសំណុំរឿងនឹងបន្តការស៊ើបសួរក្រោមសំណុំរឿងលេខ ០០១/១៨-០៧-២០០៧។

ប្រកាសថាអង្គហេតុដទៃទៀតដែលមានកំណត់នៅក្នុងដីកាបញ្ជូនរឿងអោយស៊ើបសួរចុះថ្ងៃទី ១៨ កក្កដា ឆ្នាំ ២០០៧ ដែលអង្គហេតុនេះពាក់ព័ន្ធនឹង **ឌុច** ឬ ជនផ្សេងទៀតដែលមានឈ្មោះនៅក្នុងដីកាបញ្ជូនរឿងអោយស៊ើបសួរខាងលើ នឹងត្រូវស៊ើបសួរក្រោមសំណុំរឿងលេខ ០០២/១៩-០៩-២០០៧។

ធ្វើនៅភ្នំពេញ ថ្ងៃទី១៩ខែ កញ្ញា ឆ្នាំ ២០០៧

**សហចៅក្រមស៊ើបអង្កេត**

**Co-Investigating Judges**

**Co-juges d'instruction**

**យូ ប៊ុនឡេង**

**MARCEL Lemonde**